# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ពាក្យខ្មែរមួយបទពោលថា ច្បាប់ពុំឈ្នះទម្លាប់ ។

www.hoksavann.org

ថ្ងៃទី១២ កក្កដា ២០១២



ពាក្យថា «ច្បាប់ពុំឈ្នះទម្លាប់» មានន័យថា ទម្លាប់គឺអំពើដែលធ្លាប់ធ្វើ ទោះបីច្បាប់បញ្ញត្តិហាមប្រាមមិនឲ្យធ្វើ ក៏មិនងាយលះបង់បាន ។ ពាក្យថាទម្លាប់មកពីធ្លាប់ធ្វើច្រើនដង ធ្វើយូរៗទៅក្លាយជាទំនៀម ។ ជួនកាលគេហៅជាប់ពាក្យពីរថា ទំនៀមទម្លាប់ ហើយទំនៀមទម្លាប់ធ្វើតៗគ្នាយូរៗទៅ ក្លាយជាប្រពៃណី បាលីថា បវេណី គឺប្រពៃណីរបស់ត្រកូល ឬរបស់ជាតិនីមួយៗ ។ ជួនកាលច្បាប់គេធ្វើដោយយោលទៅតាមទំនៀមទម្លាប់ប្រពៃណីរបស់ជាតិនីមួយៗដោយគ្រាន់តែកែសម្រួលឲ្យមានភាពជឿនលឿនប៉ុណ្ណោះ ប៉ុន្តែវប្បធម៌ជាគោលដើមគេនៅរក្សាទុក ដូចច្បាប់រដ្ឋប្បវេណីជាដើម ។ គេពុំបំបាត់ទំនៀមទម្លាប់ ដែលធ្លាប់មានមកហើយចោល ហើយយកមនោគមវិជ្ជាថ្មីមកជំនួសដូចកុម្មុយនិស្តខ្មែរក្រហមទេ ។

ព្រះពុទ្ធជាម្ចាស់ក្រោយពេលបានត្រាស់ដឹង ព្រះអង្គសំដែងធម៌ ហាក់ដូចជាព្រះអង្គធ្វើបដិវត្តន៍សង្គមទៅរកសច្ចធម៌ ក៏ព្រះអង្គពុំបំបាត់ពាក្យដែលគេធ្លាប់និយមប្រើមកហើយចោលទេ តែព្រះអង្គគ្រាន់តែបង្វែន័យឲ្យស្របទៅតាមការពិតប៉ុណ្ណោះ ដូចជាពាក្យថា ព្រាហ្មណ៍ ព្រះអង្គឲ្យន័យថា ដែលហៅថាព្រាហ្មណ៍ ពុំមែនព្រាហ្មណ៍ពីកំណើតទេ គឺបុគ្គលណាបន្សាត់បង់នូវអំពើបាប ទើបហៅថា សមណៈ ឬព្រាហ្មណ៍ ។

ចំពោះច្បាប់របស់ប្រទេសនីមួយៗ មានលក្ខណៈផ្សេងគ្នា ប៉ុន្តែច្បាប់ដែលពិភពលោកសព្វថ្ងៃនេះទទួលស្គាល់ថាជាច្បាប់ ឬរបបល្អត្រឹមត្រូវមានយុត្តិធម៌ គឺរបបប្រជាធិបតេយ្យសេរី និងការគោរពសិទ្ធិមនុស្ស ដោយទទួលស្គាល់ថា អំណាចដឹកនាំរដ្ឋ កើតចេញមកពីប្រជាពលរដ្ឋ ។ សព្វថ្ងៃនេះ នៅសល់របបកុម្មុយនិស្តនិងរបបផ្តាច់ការខ្លះ ប៉ុន្តែមានធម្មនុញ្ញនៃអង្គការសហប្រជាជាតិបញ្ចេញសេចក្តីថ្លែងការណ៍ ថ្កោលទោសទប់កុំឲ្យរបបនេះរំលោភសិទ្ធិមនុស្ស ។ ចំពោះច្បាប់ធម៌របស់ព្រះពុទ្ធសាសនាវិញ ព្រះពុទ្ធបានបង្រៀនឲ្យមនុស្សគោរពសិទ្ធិមនុស្ស រហូតដល់គោរពសិទ្ធិសត្វតិរច្ឆាន កុំឲ្យគេសម្លាប់ទៀតផង ដូចមានក្នុងសិក្ខាបទទី១នៃសីល៥ ។ លើសពីនេះទៀត ព្រះអង្គបង្រៀនឲ្យមនុស្សគោរពកម្មសិទ្ធិទ្រព្យសម្បត្តិអ្នកដទៃ ដោយកុំលួចកុំប្លន់ ។ ព្រះអង្គប្រៀនប្រដៅឲ្យមនុស្សស្រឡាញ់រាប់អានគ្នា ជួយសង្គ្រោះគ្នានៅពេលមានទុក្ខ ។ ព្រះអង្គឲ្យព្រះសង្ឃសំរេចកិច្ចការរបស់ព្រះសង្ឃតាមការស្រុះស្រួលគ្នា តាមព្រះវិន័យជាគោល ។

ពាក្យថា«ច្បាប់ពុំឈ្នះទម្លាប់»នេះ ពុំត្រឹមត្រូវតាមពាក្យនេះទាំងអស់ឡើយ ព្រោះទម្លាប់បើមិនធ្វើតាមក៏គ្មានទោស គ្រាន់តែឆ្គងក្នុងសង្គមប៉ុណ្ណោះ ឯច្បាប់របស់ប្រទេសវិញ បើមិនប្រព្រឹត្តតាម នឹងមានទោសធ្ងន់ស្រាលតាមបទល្មើស ។ ដូចនេះបញ្ជាក់ថា ពុទ្ធភាសិតនិងពាក្យរបស់មនុស្សធម្មតាដូចជាពាក្យរបស់ខ្មែរ មានលក្ខណៈខុសគ្នាស្រឡះ គឺពាក្យរបស់ព្រះពុទ្ធដែលហៅថាពុទ្ធភាសិត ជាពាក្យត្រឹមត្រូវ ជាពាក្យពិត ជាសច្ចៈសាកល ត្រូវគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ដូចជាពាក្យថា កើតស្លាប់ជាដើម ។ ចំណែកបុរាណសុភាសិត មិនថាតែពាក្យខ្មែរទេ ទោះពាក្យរបស់អ្នកប្រាជ្ញទស្សនវិទូក្នុងលោក ក៏មិនអាចរកឃើញសច្ចៈសាកលដូចព្រះពុទ្ធឡើយ មាននិយាយត្រូវតាមលោកិយសច្ចៈ ដូចក្រុមវិទ្យាសាស្រ្តបានរកឃើញការពិតដើម្បីបង្កើតសម្ភារៈប្រើប្រាស់ជាដើម ។ ដូច្នេះហើយបានជា គេឃើញប្រទេសនីមួយៗ តែងតែអនុវត្តការងារប្រចាំថ្ងៃស្របតាមប្រពៃណីជាតិរបស់ខ្លួន ដូចជាប្រទេសកម្ពុជា ជនជាតិខ្មែរមានគំនិត ចរិយា ការប្រព្រឹត្តទៅតាមប្រពៃណីទំនៀមទម្លាប់ព្រះពុទ្ធសាសនារបស់ជាតិខ្លួន បន្តពីជំនាន់មួយទៅជំនាន់មួយ ។ គេមិនអាចបំបាត់ទំនៀមទម្លាប់ ដែលក្លាយជាវប្បធម៌ រលាយជាសាច់ជាឈាមរបស់ជនជាតិខ្មែរបានឡើយ ។ ពួកខ្មែរក្រហមបានអនុវត្តគំនិតនេះ តែពួកវាត្រូវបរាជ័យ ។

*　　　*

*